ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រង

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦

# ជម្រាបមក

## មន្ត្រី L.O GDCE Admin ទាំងអស់

សូម Print ឯកសារលេខ ២៣៣៣/១៦ អគរ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦ ដើម្បីដាក់ជូនប្រធានអង្គភាពបានជ្រាប និងមុខការបានទាន់ពេលវេលា។ ច្បាប់ដើមមាននៅនាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រង។ សូមចាត់មន្ត្រីមកទទួលយកកុំបីខាន។

សូមអរគុណ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

លេខ : ២៣៣៣/១៦ អគរ

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៦

## ជម្រាបមក
## លោកឧកញ៉ា លោក លោកស្រី ជាអគ្គនាយក អគ្គនាយិកា
## ក្រុមហ៊ុនអាជីវកម្មនាំចូល និងចែកចាយផលិតផលតេលសិលា

**កម្មវត្ថុ** : ការបញ្ឈប់ការអនុញ្ញាតឱ្យនាំចូលផលិតផលតេលសិលាតាមមាត់ច្រកផ្លូវគោក។

**យោង** : ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ លើលិខិតលេខ ៩៩០១ សហវ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីសំណើសុំគោលការណ៍អនុវត្តចំពោះការអនុញ្ញាតឱ្យនាំចូលផលិតផលតេលសិលាតាមមាត់ច្រកផ្លូវគោក។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកឧកញ៉ា លោក លោកស្រី ជាអគ្គនាយក អគ្គនាយិកា ក្រុមហ៊ុនអាជីវកម្មនាំចូល និងចែកចាយផលិតផលតេលសិលាជ្រាបថា យោងលើស្ថានភាពកាន់តែល្អប្រសើរនៃបណ្តាញហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននៅទូទាំងប្រទេស លទ្ធភាពផ្គត់ផ្គង់ប្រេងឥន្ធនៈទៅគ្រប់រាជធានី-ខេត្តដោយក្រុមហ៊ុនធំៗនាំចូលតាមផ្លូវទឹក និងដើម្បីរក្សាបាននូវចីរភាពចំណូលពន្ធអាករ ក៏ដូចជាការចាំបាច់ចំពោះមុខក្នុងការពង្រឹងប្រសិទ្ធភាពគ្រប់គ្រង និងលើកកម្ពស់អនុលោមភាពនៃការអនុវត្តច្បាប់និងបទប្បញ្ញត្តិជាធរមាន រាជរដ្ឋាភិបាលបានសម្រេចបញ្ឈប់ការអនុញ្ញាតឱ្យនាំចូលផលិតផលតេលសិលាតាមមាត់ច្រកផ្លូវគោកជាស្ថាពរ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ តទៅ។

ក្នុងករណីនៅបន្តនាំចូលផលិតផលតេលសិលាតាមមាត់ច្រកផ្លូវគោក អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានឹងចាត់វិធានការតាមនីតិវិធីច្បាប់ជាធរមាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកឧកញ៉ា លោក លោកស្រី ជ្រាប និងចាត់ចែងអនុវត្តតាមខ្លឹមសារនៃលិខិតនេះឱ្យមានប្រសិទ្ធភាព។

សូមលោកឧកញ៉ា លោក លោកស្រី ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

**អគ្គនាយក**
**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

**បណ្ឌិត គុណ-ញឹម**

**ចម្លងជូន÷**
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់សាលាខេត្តពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសុំកិច្ចសហការផ្សព្វផ្សាយ"
- គ្រប់អង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធ "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន: លេខ ៦-៨ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ / ទូរសារ: (៨៥៥-២៣) ២១៤ ០៦៥ / ៧២៥ ១៨៧ / ២១២ ៤៥៧ / E-mail: info-pru@customs.gov.kh